លេខ ១៥ ចេញផ្សាយថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២២

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែសីហា ឆ្នាំ២០២២

និយ័តករបរធនបាលកិច្ច
គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា

## វគ្គបណ្តុះបណ្តាល និងប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចលើកទី១ ក្រុមទី២ ឆ្នាំ២០២២

នាព្រឹកថ្ងៃអង្គារ ៥កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **នង ពិសិដ្ឋ** អគ្គនាយករង នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញប្រកាសបើក "វគ្គបណ្តុះបណ្តាល និងប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចលើកទី១ ក្រុមទី២ ឆ្នាំ២០២២"។ ការរៀបចំវគ្គ-បណ្តុះបណ្តាល និងប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចនេះ គឺជាការបោះជំហានថ្មីបន្ថែមមួយទៀតក្នុងដំណើរការបង្កើតអត្ថិភាពទីផ្សារបរធនបាលកិច្ចពេញលេញនៅកម្ពុជា ដែលមានប្រតិបត្តិករ តួយ៉ាងដូចជា ក្រុមហ៊ុនបរធនបាល បរធនបាលរូបវន្តបុគ្គលឯករាជ្យ បុគ្គលិកជាន់ខ្ពស់ និងបុគ្គលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច ជាអ្នកមានគុណវុឌ្ឍិគ្រប់គ្រាន់ តាមលក្ខខណ្ឌតម្រូវក្នុងបទប្បញ្ញត្តិជាធរមាន និងស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។ កម្មវិធីនេះនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២-៥ ខែសីហា ឆ្នាំ២០២២ នៅអគារនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

## មាតិកា

❖ កិច្ចវគ្គបណ្តុះបណ្តាល និងប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចលើកទី១ ក្រុមទី២ ឆ្នាំ២០២២ ទំព័រទី១
❖ ពិធីឈរស្មឹងស្មាធិ៍គោរពវិញ្ញាណក្ខន្ធសពលោកជំទាវ នាវ ច័ន្ទថាណា ទំព័រទី២
❖ កិច្ចពិភាក្សាស្តីពី÷ទស្សនាទាននៃកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅកម្ពុជា ទំព័រទី២
❖ ការប្រឡងរបស់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី២ ទំព័រទី៣
❖ កិច្ចប្រជុំកម្រិតបច្ចេកទេស ដើម្បីពិនិត្យ និងផ្តល់យោបល់លើខ្លឹមសារនៃសេចក្តីព្រាងប្រកាសស្តីពីគោលការណ៍ណែនាំលើការវិនិយោគសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងរបស់និយ័តករធានារ៉ាប់រងកម្ពុជា ទំព័រទី៤
❖ កិច្ចពិភាក្សាស្តីពី÷ ទស្សនាទាននៃកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅកម្ពុជា ទំព័រទី៤
❖ កិច្ចពិភាក្សាស្តីពី បរធនបាលកិច្ច÷ បទពិសោធន៍អនុវត្តន៍ និងកាលានុវត្តភាព ទំព័រទី៥
❖ ការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី៣ ទំព័រទី៦
❖ ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាង និយ័តករបរធនបាលកិច្ច និងអង្គភាពសារព័ត៌មានខេមបូណ្ឌមីស ទំព័រទី៦
❖ កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំខែកក្កដា ឆ្នាំ២០២២ និងទិសដៅការងារប្រចាំខែសីហា ឆ្នាំ២០២២ របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច ទំព័រទី៦
❖ កិច្ចប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំ លើគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) ទំព័រទី៧
❖ កិច្ចប្រជុំកម្រិតបច្ចេកទេសដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករមូលបត្រកម្ពុជាសម្រាប់រយៈពេល ៥ ឆ្នាំ (២០២១-២០២៥) ទំព័រទី៧
❖ ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាងនិយ័តករបរធនបាលកិច្ច និងអគ្គនាយកនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា (ទទក) ទំព័រទី៨
❖ សិក្ខាសាលាបណ្តុះបណ្តាល និងកសាងសមត្ថភាពមន្ត្រី ស្តីពី "ភាពជាអ្នកដឹកនាំ÷ ជវភាព, ភាពរស់រវើក, តុល្យភាព" ទំព័រទី៨
❖ កិច្ចប្រជុំកម្រិតបច្ចេកទេសស្តីពី "ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច" ទំព័រទី៩
❖ ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាងនិយ័តករបរធនបាលកិច្ច និងសមាគមសហគ្រិនវ័យក្មេងកម្ពុជា (YEAC) ទំព័រទី១០
❖ កិច្ចប្រជុំពិភាក្សាការងារ អំពីការអភិវឌ្ឍ និងកាលានុវត្តភាពក្នុងវិស័យបរធនបាលកិច្ច ទំព័រទី១១
❖ កិច្ចប្រជុំបូកសរុបការងារប្រចាំខែកក្កដា និងខែសីហា ព្រមទាំងទិសដៅការងារប្រចាំខែកញ្ញា ឆ្នាំ២០២២ក្នុងកម្រិតអន្តរនាយកដ្ឋាន ទំព័រទី១២
❖ កម្មវិធីសិក្ខាសាលាស្តីពី "AmCham Tax-Breakfast" ដែលរៀបចំដោយសភាពាណិជ្ជកម្មអាមេរិកប្រចាំនៅកម្ពុជា ទំព័រទី១២
❖ កិច្ចប្រជុំពិភាក្សាការងាររវាងនិយ័តករបរធនបាលកិច្ច និងវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ (IFA) ទំព័រទី១៣



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាពក្នុងការប្រកាសបើកវគ្គបណ្តុះបណ្តាល និងប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចលើកទី ១ ក្រុមទី២ ឆ្នាំ២០២២។

## ពិធីឈរស្មឹងស្មាធិ៍គោរពវិញ្ញាណក្ខន្ធសព លោកជំទាវ នាវ ច័ន្ទថាណា

ពិធីឈរស្មឹងស្មាធិ៍គោរពវិញ្ញាណក្ខន្ធសពលោកជំទាវ **នាវ ច័ន្ទថាណា** អគ្គទេសាភិបាលរងធនាគារជាតិនៃកម្ពុជា និងជាសមាជិកានៃក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ មុនពេលបើកពិធីពិភាក្សាស្តីអំពី "ទស្សនាទាននៃកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅកម្ពុជា" នាថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ ដោយក្តីគោរព និងអាឡោះអាល័យ។




រូបភាពពិធីឈរស្មឹងស្មាធិ៍គោរពវិញ្ញាណក្ខន្ធសពលោកជំទាវ **នាវ ច័ន្ទថាណា**

## កិច្ចពិភាក្សាស្តីពី៖ ទស្សនាទាននៃកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅកម្ពុជា ក្នុងកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិ ក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី២

កាលពីរសៀលថ្ងៃព្រហស្បតិ៍ ៧កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមដឹកនាំ និងសម្របសម្រួលកិច្ចពិភាក្សាស្តីពី៖ ទស្សនាទាននៃកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធន-បាលកិច្ចនៅកម្ពុជា ក្នុងកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី២ នៅអគារនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។ កិច្ចពិភាក្សានេះ មានការអញ្ជើញចូលរួមដោយវាគ្មិនកិត្តិយសដែលសុទ្ធសឹងជាអ្នកជំនាញក្នុងវិស័យបរធនបាលកិច្ច និងវិស័យហិរញ្ញវត្ថុ រួមមាន៖ លោក **ប៊ុន យិន** ប្រធាននាយក ប្រតិបត្តិធនាគារ ស៊ីអាយអឹមប៊ី ភីអិលស៊ី, លោកស្រី **ម៉ារ អមរា** អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់

និងជាគណៈប្រធាននាយិកា ប្រតិបត្តិហិរញ្ញវត្ថុ នៃធនាគារ អេស៊ីលីដា ភីអិលស៊ី, ឯកឧត្តម **អ៊ុក រី** អភិបាលនៃក្រុមហ៊ុន យ័ន ហាន ត្រាស អ៊ិនវេសមិ៊ន ឯ.ក និង លោក **ជា ហាង** ប្រធានក្រុមបរធនបាលនៃបរធនបាលកិច្ចហិរញ្ញវត្ថុប្រាសាក់។ នៅក្នុងកិច្ចពិភាក្សានេះ វាគ្មិនកិត្តិយសបានធ្វើការពិភាក្សាអំពីទស្សនាទាននៃការបង្កើតវិស័យបរធនបាលកិច្ចនៅកម្ពុជា តាមរយៈការចែករំលែកបទពិសោធន៍អនុវត្តន៍ បញ្ហាប្រឈម កាលានុវត្តភាព ការដកស្រង់បទពិសោធន៍ខ្លះនៃការអភិវឌ្ឍវិស័យធនាគារសម្រាប់ជាវិភាគទានដល់កិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅកម្ពុជា ការពិភាក្សាអំពីទិដ្ឋភាពផ្នែកច្បាប់ និងការអនុវត្ត ក៏ដូចជាសក្តានុពលនៃវិស័យបរធនបាលកិច្ច។ ជារួម វាគ្មិនទាំងអស់បានសម្តែងការសាទរដល់កិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច រួមទាំងការបង្កើតនិយ័តករបរធនបាលកិច្ច និងការដាក់ឱ្យអនុវត្តនូវបទដ្ឋានគតិយុត្តថ្មីៗ និងមានទស្សនាទានវិជ្ជមានចំពោះសក្តានុពល ក៏ដូចជាប្រតិបត្តិការបរធនបាលកិច្ច ដែលនឹងចូលរួមជំរុញ និងគាំទ្រការអភិវឌ្ឍវិស័យផ្សេងៗទៀតនៅក្នុងសេដ្ឋកិច្ច និងសង្គមកម្ពុជា។




រូបភាពកិច្ចពិភាក្សាស្តីពី៖ ទស្សនាទាននៃកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅកម្ពុជា ក្នុងកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី២។

## ការប្រឡងរបស់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី២

ប្រឡងបុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធន-បាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី២ ដែលបានប្រព្រឹត្តទៅនៅព្រឹកថ្ងៃសុក្រ ៨កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២ នៅអគារនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។




រូបភាពការប្រឡងរបស់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធន-បាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី២។

## កិច្ចប្រជុំកម្រិតបច្ចេកទេស ដើម្បីពិនិត្យ និងផ្ដល់យោបល់លើខ្លឹមសារនៃសេចក្ដីព្រាងប្រកាសស្ដីពីគោលការណ៍ណែនាំលើការវិនិយោគសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងរបស់និយ័តករធានារ៉ាប់រងកម្ពុជា

នារសៀលថ្ងៃចន្ទ ១១កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច **(ន.ប.ធ.)** អមដោយកញ្ញា **ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច, លោក **ហាយ សុវណ្ណា** ប្រធានស្ដីទីនាយកដ្ឋានចុះបញ្ជី បរធនបាលកិច្ច និងសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ **(អ.ស.ហ.)** ដើម្បីពិនិត្យ និងផ្ដល់យោបល់លើខ្លឹមសារនៃសេចក្ដី-ព្រាងប្រកាសស្ដីពីគោលការណ៍ណែនាំលើការវិនិយោគសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងរបស់និយ័តករធានារ៉ាប់រងកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **រស់ សីលវ៉ា** អនុប្រធាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។



រូបភាពកិច្ចប្រជុំកម្រិតបច្ចេកទេស ដើម្បីពិនិត្យ និងផ្ដល់យោបល់លើខ្លឹមសារនៃសេចក្ដីព្រាងប្រកាសស្ដីពីគោលការណ៍ណែនាំលើការវិនិយោគសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងរបស់និយ័តករធានារ៉ាប់រងកម្ពុជា។

## វគ្គបណ្ដុះបណ្ដាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចលើកទី ១ ក្រុមទី៣ ឆ្នាំ២០២២

នាព្រឹកថ្ងៃអង្គារ ១២ កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច **(ន.ប.ធ.)** អមដោយសហការី បានអញ្ជើញប្រកាសបើក "វគ្គបណ្ដុះបណ្ដាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចលើកទី១ ក្រុមទី៣ ឆ្នាំ២០២២"។ ការរៀបចំវគ្គ-បណ្ដុះបណ្ដាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចនេះ គឺជាការបោះជំហានថ្មីបន្ថែមមួយទៀត ក្នុងដំណើរការបង្កើតអត្ថិភាពទីផ្សារបរធនបាលកិច្ចពេញលេញនៅកម្ពុជា ដែលមានប្រតិបត្តិករ តួយ៉ាងដូចជា ក្រុមហ៊ុនបរធនបាល បរធនបាលរូបវន្តបុគ្គលឯករាជ្យ បុគ្គលិកជាន់ខ្ពស់ និងបុគ្គលផ្ដល់សេវាក្នុងវិស័យបរធនបាលកិច្ច ជាអ្នកមានគុណវុឌ្ឍិគ្រប់គ្រាន់ តាមលក្ខខណ្ឌតម្រូវក្នុងបទប្បញ្ញត្តិជាធរមាន និងស្របតាមឧត្តម្ភានុវត្តន៍អន្តរជាតិ។ កម្មវិធីនេះនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី៩-១២ ខែសីហា ឆ្នាំ២០២២ នៅអគារនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ **(អ.ស.ហ.)**។

វគ្គបណ្ដុះបណ្ដាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុង វិស័យបរធនបាលកិច្ច លើកទីមួយ ឆ្នាំ ២០២២ ទាំងបីក្រុមនេះ មានអ្នកចូលរួមសរុបចំនួន ២៦៣ នាក់។



រូបភាពវគ្គបណ្ដុះបណ្ដាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចលើកទី ១ ក្រុមទី៣ ឆ្នាំ២០២២



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចពិភាក្សាស្តីពី "បរធនបាលកិច្ច៖ បទពិសោធន៍អនុវត្តន៍ និងកាលានុវត្តភាព" ក្នុងកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី៣

កាលពីរសៀលថ្ងៃព្រហស្បតិ៍ ១៤កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមដឹកនាំ និងសម្របសម្រួលកិច្ចពិភាក្សាស្តីពី "បរធនបាលកិច្ច៖ បទពិសោធន៍អនុវត្តន៍ និងកាលានុវត្តភាព" ក្នុងកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី៣ នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

កិច្ចពិភាក្សានេះ មានការអញ្ជើញចូលរួមដោយវាគ្មិនកិត្តិយសដែលសុទ្ធសឹងជាអ្នកជំនាញក្នុងវិស័យបរធនបាលកិច្ច និងវិស័យហិរញ្ញវត្ថុ រួមមាន៖ លោកឧកញ៉ា **ហួត អៀងតុង** ប្រធានអគ្គនាយកធនាគារហត្ថាកសិករ និងជាប្រធានក្រុមបរធនបាលនៃបរធនបាលកិច្ចហិរញ្ញវត្ថុហត្ថាកសិករ, លោកឧកញ៉ាបណ្ឌិត **ប៊ុន មុនី** ប្រធានក្រុមបរធនបាលកិច្ចហិរញ្ញវត្ថុស្ថាបនាសហគមន៍កម្ពុជា, ឯកឧត្តម **ផូវ សំភី** អ្នកជំនាញការច្បាប់ និងជាប្រធានក្រុមប្រឹក្សាភិបាលរបស់បរធនបាលកិច្ចហិរញ្ញវត្ថុ សីលានិធិ និងលោក **ចាន់ ម៉ាច** អគ្គនាយកធនាគារ ហ្វីលីព ភីអិលស៊ី និងជាប្រធានក្រុមប្រឹក្សាភិបាលបរធនបាលកិច្ចហិរញ្ញវត្ថុក្រេឌីត។

នៅក្នុងកិច្ចពិភាក្សានេះ វាគ្មិនកិត្តិយសបានធ្វើការពិភាក្សាអំពីទស្សនាទាននៃការដាក់ឲ្យអនុវត្តប្រតិបត្តិការបរធនបាលកិច្ចនៅកម្ពុជា តាមរយៈការចែករំលែកបទពិសោធន៍អនុវត្តន៍ បញ្ហាប្រឈម កាលានុវត្តភាព ការពិភាក្សាអំពីទិដ្ឋភាពផ្នែកច្បាប់ និងការអនុវត្ត មុននិងក្រោយពេលមានច្បាប់ស្តីពីបរធនបាលកិច្ច ក៏ដូចជាសក្តានុពលនៃវិស័យបរធនបាលកិច្ចក្នុងការជួយជំរុញប្រតិបត្តិការរំហូរមូលធន, ប្រតិបត្តិការវិនិយោគអចលនទ្រព្យ, ការរៀបចំផែនការស្តិរភាពហិរញ្ញវត្ថុគ្រួសារ និងបុគ្គលជាដើម។ ជារួម វាគ្មិនទាំងអស់បានសម្តែងការសាទរដល់កិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច រួមទាំងការបង្កើតនិយ័តករបរធនបាលកិច្ច និងការដាក់ឱ្យអនុវត្តនូវបទដ្ឋានគតិយុត្តថ្មីៗ និងមានទស្សនាទានវិជ្ជមានចំពោះសក្តានុពលនៃវិស័យបរធនបាលកិច្ច ក៏ដូចជាប្រតិបត្តិការបរធនបាលកិច្ច ដែលនឹងចូលរួមជំរុញ និងគាំទ្រការអភិវឌ្ឍវិស័យផ្សេងៗទៀតនៅក្នុងសេដ្ឋកិច្ច និងសង្គមកម្ពុជា។




រូបភាពកិច្ចពិភាក្សាស្តីពី "បរធនបាលកិច្ច៖ បទពិសោធន៍អនុវត្តន៍ និងកាលានុវត្តភាព" ក្នុងកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី៣។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី៣

ការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី៣ ដែលបានប្រព្រឹត្តទៅនៅព្រឹកថ្ងៃសុក្រ ១៥កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ នៅអគារនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។




រូបភាពការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី៣

## ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាង និយ័តករបរធនបាលកិច្ច និងអង្គភាពសារព័ត៌មានខេមបូណ្ឌមីស

កាលពីព្រឹកថ្ងៃអង្គារ ៤រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)** ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងលោក **ស៊ីន សាយ** នាយកប្រតិបត្តិនៃសារព័ត៌មាន ខេមបូណ្ឌមីស បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្ដីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងជំរុញការចូលរួមក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។ គោល-បំណងនៃការចុះអនុស្សរណៈនៃការយោគយល់គ្នានេះ គឺដើម្បីបង្កើតកិច្ចសហការក្នុងភាពជាដៃគូជាមួយអង្គភាពសារព័ត៌មានខេមបូណ្ឌមីស ក្នុងការបង្កើនការជំរុញ និងលើកកម្ពស់ការយល់ដឹងបន្ថែម ក៏ដូចជាដើម្បីបញ្ជ្រាបការយល់ដឹងអំពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា យន្តការបរធនបាលកិច្ច លក្ខខណ្ឌតម្រូវក្នុងការធ្វើប្រតិបត្តិការ បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងផលប្រយោជន៍ដែលអាចទាញយកចេញពីប្រតិបត្តិការបរធនបាលកិច្ច ការបង្កើតនិងបង្កើនទំនុកចិត្តតាមរយៈការបង្កើតបរធនបាលកិច្ចក្នុងធុរកិច្ចពាក់ព័ន្ធ និងក្នុងប្រតិបត្តិការរំហូរមូលធនទៅគ្រប់វិស័យក្នុងសេដ្ឋកិច្ច និងសង្គមកម្ពុជា។ ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នានេះ មានការអញ្ជើញចូលរួមពីតំណាងនៃនិយ័តករក្រោមឱវាទនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ក្រុមហ៊ុនបរធនបាល និងក្រុមហ៊ុនផ្ដល់សេវាក្នុងវិស័យបរធនបាលកិច្ចផងដែរ។




រូបភាពពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាង និយ័តករបរធនបាលកិច្ច និងអង្គភាពសារព័ត៌មានខេមបូណ្ឌមីស។

## កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំខែកក្កដា ឆ្នាំ២០២២ និងទិសដៅការងារប្រចាំខែសីហា ឆ្នាំ២០២២ របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច

នាព្រឹកថ្ងៃពុធ ៥ រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ណឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច បានដឹកនាំកិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំខែកក្កដា ឆ្នាំ២០២២ និងទិសដៅការងារប្រចាំខែសីហា ឆ្នាំ២០២២ របស់នាយកដ្ឋានចុះបញ្ជី



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

បរធនបាលកិច្ច ដោយមានការចូលរួមពីលោក **ហាយ សុវណ្ណា** ប្រធាននាយកដ្ឋានស្តីទី, អនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ ព្រមទាំងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច។ នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយករងបានផ្តល់អនុសាសន៍ និងតម្រង់ទិសការងារមួយចំនួនសម្រាប់អនុវត្តនៅក្នុងខែបន្ទាប់។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅដោយរលូន និងប្រកបដោយផ្លែផ្កាខ្ពស់។



រូបភាពកិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំខែកក្កដា ឆ្នាំ២០២២ និងទិសដៅការងារប្រចាំខែសីហា ឆ្នាំ២០២២ របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច។

## កិច្ចប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំ លើគម្រោងចំណូលចំណាយថវិកាឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)

នាព្រឹកថ្ងៃព្រហស្បតិ៍ ៦រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដាវ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**និ.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំ លើគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) នៅសាលប្រជុំ អគារ យ នៃទីស្តីការ កសហវ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **វង្សី វិស្សុត** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការនៃ កសហវ។

កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមដោយផ្ទាល់ពីថ្នាក់ដឹកនាំនៃ កសហវ ព្រមទាំងថ្នាក់ដឹកនាំអង្គភាពថវិកាស្ថិតក្រោមឱវាទ កសហវ។



រូបភាពកិច្ចប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំ លើគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)។

## កិច្ចប្រជុំកម្រិតបច្ចេកទេសដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករមូលបត្រកម្ពុជាសម្រាប់រយៈពេល ៥ ឆ្នាំ (២០២១-២០២៥) ប្រកាសស្តីពីកាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ និងផែនការអភិវឌ្ឍន៍ស្ថាប័ននៃនិយ័តករសន្តិសុខសង្គម (២០២២-២០២៦)

នារសៀលថ្ងៃសុក្រ ៧រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដាវ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**និ.ប.ធ.**) អមដោយ កញ្ញា **ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច និងលោក **ណង សេរីវុធ** អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករមូលបត្រកម្ពុជាសម្រាប់រយៈពេល ៥ ឆ្នាំ (២០២១-២០២៥) ប្រកាសស្តីពីកាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ និងផែនការអភិវឌ្ឍន៍ស្ថាប័ននៃនិយ័តករសន្តិសុខសង្គម (២០២២-២០២៦) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **រស់ សីលវ៉ា** អនុប្រធាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh  www.facebook.com/trustregulatorcambodia  (855) 23 237 888



រូបភាពកិច្ចប្រជុំកម្រិតបច្ចេកទេសដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករមូលបត្រកម្ពុជាសម្រាប់រយៈពេល ៥ ឆ្នាំ (២០២១-២០២៥) ប្រកាសស្តីពីកាតព្វកិច្ចផ្តល់របាយការណ៍ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ និងផែនការអភិវឌ្ឍន៍ស្ថាប័ននៃនិយ័តករសន្តិសុខសង្គម (២០២២-២០២៦)។

## ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាងនិយ័តករបរធនបាលកិច្ច និងអគ្គនាយកនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា (ទទក)

នាព្រឹកថ្ងៃអង្គារ ១១រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)** ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងឯកឧត្តម **ឃឹម ឫទ្ធី** អគ្គនាយកនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា (**ទទក**) បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងជំរុញការចូលរួមក្នុងវិស័យបរធនបាលកិច្ចនៅ ព្រះរាជាណាចក្រកម្ពុជា"។ គោលបំណងនៃការចុះអនុស្សរណៈនៃការយោគយល់គ្នានេះ គឺដើម្បីបង្កើតកិច្ចសហការក្នុងភាពជាដៃគូរវាងស្ថាប័នរដ្ឋទាំងពីរក្នុងការជំរុញ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យបរធនបាលកិច្ច នៅប្រទេសកម្ពុជា តាមរយៈការបង្កើតកម្មវិធីផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងអំពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា យន្តការប្រតិបត្តិការបរធនបាលកិច្ច លក្ខខណ្ឌតម្រូវនិង បទដ្ឋានគតិយុត្តពាក់ព័ន្ធការបង្កើតនិងបង្កើនទំនុកចិត្តតាមរយៈការបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនិងផលប្រយោជន៍ដែលអាចទាញយកចេញពីប្រតិបត្តិការបរធនបាលកិច្ចក្នុងធុរកិច្ចពាក់ព័ន្ធនិងក្នុងប្រតិបត្តិការរំហូរមូលធនទៅគ្រប់វិស័យក្នុងសេដ្ឋកិច្ច និងសង្គមកម្ពុជា។

ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នានេះ មានការអញ្ជើញចូលរួមពីឯកឧត្តម **ម៉ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យ និងសវនកម្ម, លោកជំទាវ **កុច មារតី** អគ្គនាយករងនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា, និងតំណាងនៃនិយ័តករក្រោមឱវាទនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** និង **ទទក**, ក្រុមហ៊ុនបរធនបាល និងបុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ចផងដែរ។



រូបភាពក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាងនិយ័តករបរធនបាលកិច្ច និងអគ្គនាយកនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា (ទទក)។

## សិក្ខាសាលាបណ្តុះបណ្តាល និងកសាងសមត្ថភាពមន្ត្រី ស្តីពី "ភាពជាអ្នកដឹកនាំ៖ ជវភាព, ភាពរស់រវើក, តុល្យភាព"

នារសៀលថ្ងៃអង្គារ ១១រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) សហការជាមួយនិយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាល និងកសាងសមត្ថភាពមន្ត្រី ស្តីពី "ភាពជាអ្នកដឹកនាំ៖ ជវភាព, ភាពរស់រវើក, តុល្យភាព" ក្នុងគោលបំណងបញ្ជ្រាបការយល់ដឹង និងបង្កើនសមត្ថភាព ក៏ដូចជាទទួលបាននូវចំណេះដឹង និងបទពិសោធន៍បន្ថែមទៀតពាក់ព័ន្ធភាពជាអ្នកដឹកនាំដល់ថ្នាក់ដឹកនាំ និងមន្ត្រីរបស់ **ន.ប.ធ.** និង **ន.ម.ក.** សរុបប្រមាណ



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

១៥០នាក់ នៅទីស្ដីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

សិក្ខាសាលានេះ មានការចូលរួមពីវាគ្មិនកិត្តិយស រួមមាន៖ ឯកឧត្តមបណ្ឌិត **ហួត ពុំ** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិកាដ្ឋានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តម **ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ **ន.ម.ក.** និង ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** ដែលបានធ្វើបទបង្ហាញ និងពិភាក្សាលើប្រធានបទភាពជាអ្នកដឹកនាំសម្រាប់ខ្លួនឯង ភាពជាអ្នកដឹកនាំសម្រាប់ស្ថាប័ន និងបទពិសោធន៍អនុវត្តន៍ភាពជាអ្នកដឹកនាំពីប្រទេសសិង្ហបុរី ហើយត្រូវបានចូលរួមយ៉ាងសកម្ម និងផុសផុលពីសិក្ខាកាម ព្រមទាំងបានបញ្ចប់ប្រកបដោយផ្លែផ្កាខ្ពស់។



រូបភាពសិក្ខាសាលាបណ្ដុះបណ្ដាល និងកសាងសមត្ថភាពមន្ត្រី ស្ដីពី "ភាពជាអ្នកដឹកនាំ៖ ជវភាព, ភាពរស់រវើក, តុល្យភាព"។

## កិច្ចប្រជុំកម្រិតបច្ចេកទេសដើម្បីទទួលបាននូវមតិយោបល់ក៏ដូចជាធាតុចូលបន្ថែមលើខ្លឹមសារនៃសេចក្ដីព្រាងប្រកាសស្ដីពី "ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច"

នារសៀលថ្ងៃព្រហស្បតិ៍ ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តមអគ្គនាយករង **ណឺ សាគល**, លោក **ហាយ សុវណ្ណ** ប្រធានស្ដីទីនៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច, កញ្ញា **ឈាន សុខារី** ប្រធាននាយដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច និងមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីទទួលបាននូវមតិយោបល់ក៏ដូចជាធាតុចូលបន្ថែមលើខ្លឹមសារនៃសេចក្ដីព្រាងប្រកាសស្ដីពី "ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច" ដើម្បីឱ្យសេចក្ដីព្រាងប្រកាសខាងលើកាន់តែមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយ សំដៅធានាឱ្យបានសុក្រឹតភាព នៃតម្លៃបរធនបាលកិច្ច ដែលបានបង្កើត និងចុះបញ្ជីបរធនបាលកិច្ចក្នុងវិស័យបរធនបាលកិច្ច។ កិច្ចប្រជុំនេះត្រូវបានធ្វើឡើង ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **វង់ សីលវ៉ា** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សានៃ **អ.ស.ហ.** និងមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករ និងអង្គភាពក្រោមឱវាទនៃ **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។



រូបភាពកិច្ចប្រជុំកម្រិតបច្ចេកទេសដើម្បីទទួលបាននូវមតិយោបល់ ក៏ដូចជាធាតុចូលបន្ថែមលើខ្លឹមសារនៃសេចក្តីព្រាងប្រកាសស្តីពី "ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច"។

## ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាងនិយ័តករបរធនបាលកិច្ច និងសមាគមសហគ្រិនវ័យក្មេងកម្ពុជា (YEAC)

នារសៀលថ្ងៃសុក្រ ១៤រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និយ័តករបរធនបាលកិច្ច (ន.ប.ធ.)** បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយសមាគមសហគ្រិនវ័យក្មេងកម្ពុជា (YEAC) ស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងជំរុញការចូលរួមក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពរបស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច និង លោក **ស៊ាន សុបញ្ញា** ប្រធានក្រុមប្រឹក្សាសមាគមសហគ្រិនវ័យក្មេងកម្ពុជា។

ការចុះអនុស្សរណៈនៃការយោគយល់គ្នានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណង៖ (១) បញ្ជ្រាប និងលើកកម្ពស់ការយល់ដឹងអំពី វិស័យបរធនបាលកិច្ចដល់សមាជិករបស់ YEAC ដែលជាសមាគមសហគ្រិនវ័យក្មេង ឱ្យមានលទ្ធភាព សមស្របដើម្បីរៀបចំខ្លួនក្នុងការចូលរួមវិនិយោគក្នុងវិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា ក៏ដូចជាការពង្រឹងការគ្រប់គ្រង ការរៀបចំ និងការធ្វើប្រតិបត្តិការបរធនបាលកិច្ច (២) អភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា តាមរយៈការលើកកម្ពស់ការយល់ដឹង ការត្រៀមខ្លួននិងការធ្វើប្រតិបត្តិការបរធនបាលកិច្ចព្រមទាំងការលើកទឹកចិត្ត និងជំរុញ សហគ្រិនវ័យក្មេងនៅកម្ពុជាចូលរួមផ្សព្វផ្សាយអំពីវិស័យបរធនបាលកិច្ច ក៏ដូចជាចូលរួមវិនិយោគក្នុងវិស័យនេះផងដែរ និង (៣) ពង្រឹង និងអភិវឌ្ឍសហគ្រិនវ័យក្មេងនៅកម្ពុជា តាមរយៈការជួយដល់សមាជិករបស់ខ្លួនឱ្យទទួលបានការយល់ដឹងបន្ថែមអំពីការអភិវឌ្ឍថ្មីៗនៃវិស័យហិរញ្ញវត្ថុ បង្កើននូវជម្រើសវិនិយោគតាមរយៈប្រភពនានា ពង្រឹងការគ្រប់គ្រង ការរៀបចំ និងការធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងបរធនបាលកិច្ច ព្រមទាំងមានបំណងចូលរួមចំណែកជំរុញដល់ការអភិវឌ្ឍ សេដ្ឋកិច្ចជាតិ ដោយផ្អែកតាមប្រព័ន្ធទីផ្សារ។

ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នានេះ មានការអញ្ជើញចូលរួមពីតំណាងនៃនិយ័តករក្រោមឱវាទនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** ប្រធាន/នាយកប្រតិបត្តិ ថ្នាក់ដឹកនាំ ក្រុមហ៊ុនដែលជាសមាជិក-សមាជិកាសមាគមសហគ្រិនវ័យក្មេង ក្រុមហ៊ុនបរធនបាល និងបុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ចផងដែរ។ កម្មវិធីត្រូវបានបញ្ចប់ទៅដោយភាពរលូន និងប្រកបដោយ ផ្លែផ្កា ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។ធ្វើប្រតិបត្តិការបរធនបាលកិច្ច (២) អភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា តាមរយៈការលើកកម្ពស់ការយល់ដឹង ការត្រៀមខ្លួន និងការធ្វើប្រតិបត្តិការបរធនបាលកិច្ច ព្រមទាំងការលើកទឹកចិត្ត និងជំរុញ សហគ្រិនវ័យក្មេងនៅកម្ពុជាចូលរួមផ្សព្វផ្សាយអំពីវិស័យបរធនបាលកិច្ច ក៏ដូចជាចូលរួមវិនិយោគក្នុងវិស័យនេះផងដែរ និង (៣) ពង្រឹង និងអភិវឌ្ឍសហគ្រិនវ័យក្មេងនៅកម្ពុជា តាមរយៈការជួយដល់សមាជិករបស់ខ្លួនឱ្យទទួលបានការយល់ដឹងបន្ថែមអំពីការអភិវឌ្ឍថ្មីៗនៃវិស័យហិរញ្ញវត្ថុ បង្កើននូវជម្រើសវិនិយោគតាមរយៈប្រភពនានា ពង្រឹងការគ្រប់គ្រង ការរៀបចំ និងការធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងបរធន-បាលកិច្ច ព្រមទាំងមានបំណងចូលរួមចំណែកជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយផ្អែកតាមប្រព័ន្ធទីផ្សារ។ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នានេះ មានការអញ្ជើញចូលរួមពីតំណាងនៃនិយ័តករក្រោមឱវាទនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** ប្រធាន/នាយកប្រតិបត្តិ ថ្នាក់ដឹកនាំ ក្រុមហ៊ុនដែលជាសមាជិក-សមាជិកាសមាគមសហគ្រិនវ័យក្មេង ក្រុមហ៊ុនបរធនបាលនិងបុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ចផងដែរ។ កម្មវិធីត្រូវបានបញ្ចប់ទៅដោយភាពរលូន និងប្រកបដោយ ផ្លែផ្កា ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។




រូបភាពពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) រវាងនិយ័តករបរធនបាលកិច្ច និងសមាគមសហគ្រិនវ័យក្មេងកម្ពុជា (YEAC)

## កិច្ចប្រជុំពិភាក្សាការងារ អំពីការអភិវឌ្ឍ និងកាលានុវត្តភាពក្នុងវិស័យបរធនបាលកិច្ច

នាព្រឹកថ្ងៃចន្ទ ៣ កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយលោក **ហាយ សុវណ្ណា** ប្រធានស្តីទីនៃនាយកដ្ឋានចុះបញ្ជីបរធន-បាលកិច្ច, កញ្ញា **ឈាន សុខារី** ប្រធាននាយដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច និងមន្ត្រីជំនាញនៃ **ន.ប.ធ.** បានទទួលជួបប្រជុំពិភាក្សាការងារជាមួយគណៈប្រតិភូនៃ Zillennium Co., Ltd ដែលដឹកនាំដោយ **លី លាង** នាយកប្រតិបត្តិក្រុមហ៊ុន ហ្សីលាន ត្រាស់ ម.ក ដោយមានការចូលរួមពីថ្នាក់ដឹកនាំនៃ Zillennium Co., Ltd, ក្រុមហ៊ុន ហ្សីលាន ត្រាស់ ម.ក, ក្លឹបអ្នកវិនិយោគកម្ពុជា, សមាគមអ្នកវាយតម្លៃនិងភ្នាក់ងារអចលនវត្ថុកម្ពុជា ដើម្បីពិភាក្សាអំពីការអភិវឌ្ឍនិងកាលានុវត្តភាពក្នុងវិស័យបរធនបាលកិច្ចក៏ដូចជាគំនិតផ្តួចផ្តើមមួយចំនួនក្នុងការជំរុញការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា។




រូបភាពកិច្ចប្រជុំពិភាក្សាការងារ អំពីការអភិវឌ្ឍ និងកាលានុវត្តភាពក្នុងវិស័យបរធនបាលកិច្ច

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែកក្កដា និងខែសីហា ព្រមទាំងទិសដៅការងារប្រចាំខែកញ្ញា ឆ្នាំ២០២២ ក្នុងកម្រិតអន្តរនាយកដ្ឋាន

នាព្រឹកថ្ងៃអង្គារ ៤កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ឆន ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែកក្កដា និងខែសីហា ព្រមទាំងទិសដៅការងារប្រចាំខែកញ្ញា ឆ្នាំ២០២២ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាន នាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ។ កិច្ចប្រជុំនេះ មានការចូលរួមពីប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យនិងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។ នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែកក្កដា និងខែសីហា ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាពកិច្ចកិច្ចប្រជុំបូកសរុបការងារប្រចាំខែកក្កដា និងខែសីហា ព្រមទាំងទិសដៅការងារប្រចាំខែកញ្ញា ឆ្នាំ២០២២ ក្នុងកម្រិតអន្តរនាយកដ្ឋាន ដឹកនាំដោយ ឯកឧត្តម **ឆន ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច។

## កម្មវិធីសិក្ខាសាលាស្តីពី "AmCham Tax – Breakfast" ដែលរៀបចំដោយសភាពាណិជ្ជកម្មអាមេរិកប្រចាំនៅកម្ពុជា

នៅព្រឹកថ្ងៃអង្គារ ៤កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមជាគណៈអធិបតី និងបានថ្លែងនូវមតិបើកសិក្ខាសាលាស្តីពី "AmCham Tax – Breakfast" ដែលរៀបចំដោយសភាពាណិជ្ជកម្មអាមេរិកប្រចាំនៅកម្ពុជា ព្រមទាំងមានការចូលរួមពីលោក Anthony Galliano ប្រធានសភាពាណិជ្ជកម្មអាមេរិកប្រចាំនៅកម្ពុជាផងដែរ។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយពីច្បាប់ស្តីពីបរធនបាលកិច្ច និងប្រធានបទពាក់ព័ន្ធនឹងពន្ធដារនៅក្នុងវិស័យបរធនបាលកិច្ចពីបណ្តាប្រទេសក្នុងតំបន់ និងក្នុងប្រទេសកម្ពុជាផងដែរ។ សិក្ខាសាលានេះ មានអ្នកចូលរួមសរុបចំនួន ១០០ រូប ដែលជាថ្នាក់ដឹកនាំនៃក្រុមហ៊ុនអចលនវត្ថុ ធនាគារ ការិយាល័យមេធាវី ក្រុមហ៊ុនបរធនបាល ក្រុមហ៊ុនធានារ៉ាប់រង និងវិទ្យាស្ថានអប់រំ ជាដើម។




រូបភាពកម្មវិធីសិក្ខាសាលាស្តីពី "AmCham Tax – Breakfast" ដែលរៀបចំដោយសភាពាណិជ្ជកម្មអាមេរិកប្រចាំនៅកម្ពុជា។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំពិភាក្សាការងាររវាងនិយ័តករបរធនបាលកិច្ច និងវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ (IFA)

នារសៀលថ្ងៃពុធ ៥កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានទទួលជួបពិភាក្សាការងារជាមួយវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ (IFA) តំណាងដោយលោក **ម៉ុន សុនន្ទវឌ្ឍ** នាយករងវិទ្យាស្ថាន អមដោយសហការី ដើម្បីពិនិត្យលទ្ធភាពក្នុងការបង្កើតកិច្ចសហប្រតិបត្តិការលើការពង្រឹង និងបង្កើនសមត្ថភាពមន្ត្រីនៃ **ន.ប.ធ.** តាមរយៈការបណ្តុះបណ្តាល និងចែករំលែកជំនាញវិភាគហិរញ្ញវត្ថុ ក៏ដូចជាក្នុងការពង្រីកវិសាលភាពនៃការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យបរធនបាលកិច្ចនៅប្រទេសកម្ពុជា ឱ្យបានទៅដល់សិស្ស-និស្សិត អំពីប្រតិបត្តិការបរធនបាលកិច្ច, កិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច, តួអង្គពាក់ព័ន្ធ, ច្បាប់និងបទប្បញ្ញត្តិ និងជាពិសេសយល់ដឹងពីគុណប្រយោជន៍របស់វិស័យបរធនបាលកិច្ចសម្រាប់សេដ្ឋកិច្ចជាតិ និងសង្គម។










រូបភាពកិច្ចប្រជុំពិភាក្សាការងាររវាងនិយ័តករបរធនបាលកិច្ច និងវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ (IFA)។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888